ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិ

រៀបចំបុណ្យជាតិ_អន្តរជាតិ

លេខៈ០៥/២០១៧ គជបអ

# ផែនការណែនាំ

## ស្តីពីការចាត់តាំងរៀបចំទិវាសន្តិភាពអន្តរជាតិ លើកទី ១៥

## ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៧

<u>យោង</u> : តាមសេចក្តីសម្រេចលេខ៥៥/២៨២ ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០០១ របស់មហាសន្និបាតអង្គការសហប្រជាជាតិ ដែលអំពាវនាវដល់គ្រប់ប្រទេសជាសមាជិកអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ឲ្យប្រារព្ធទិវាសន្តិភាពអន្តរជាតិ ២១ កញ្ញា ជារៀងរាល់ឆ្នាំ ដើម្បីជំរុញការអប់រំ និងបំផុសការយល់ដឹងជាសាធារណៈ អំពីសន្តិភាពក្នុងពិភពលោក ក្នុងតំបន់ និងក្នុងប្រទេសនីមួយៗចាត់ទុកថា ថ្ងៃទី ២១ ខែកញ្ញា ជាថ្ងៃគ្មានអំពើហិង្សា និងបញ្ឈប់ការផ្ទុះអាវុធនៅទូទាំងប្រទេស ។

-អនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើត "ទិវាសន្តិភាពអន្តរជាតិ" ដោយកំណត់យកថ្ងៃទី ២១ ខែកញ្ញា រៀងរាល់ឆ្នាំសម្រាប់រៀបចំពិធីបុណ្យនៅទូទាំងប្រទេស ក្នុងគោលបំណងពង្រឹងឧត្តមគតិសន្តិភាពរបស់ប្រជាជាតិ និងប្រជាជនទាំងអស់ក្នុងពិភពលោក សំដៅកាត់បន្ថយភាពតានតឹង ដោយអំពាវនាវឲ្យគ្រប់ប្រជាជាតិ និងប្រជាជនទាំងអស់បញ្ឈប់អំពើហិង្សា និងភាពប្រទូសរ៉ាយ ដែលបង្កឲ្យមានវិវាទ ។

-សារាចរណែនាំសម្រាប់អនុវត្តជាអចិន្ត្រៃយ៍លេខ ០៩ សរណន ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំចាត់តាំងព្រះរាជពិធីបុណ្យទ្វាទសមាស បុណ្យប្រពៃណីជាតិ ប្រពៃណីសាសនា បុណ្យជាតិ-បុណ្យអន្តរជាតិ ។

ឆ្លើយតបទៅនឹងគោលបំណង សំណូមពរនៃអនុក្រឹត្យ សារាចរណែនាំ និងសេចក្តីសម្រេចដូចខាងលើ **គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ** សូមធ្វើការណែនាំដូចតទៅ៖

**១-<u>ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ</u>** ត្រូវស្រាវជ្រាវចងក្រងខ្លឹមសារឯកសារ សម្រាប់បម្រើការរៀបចំពិធីបុណ្យទាំងមូល ដោយមានសារមួយសម្រាប់ថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិ ផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ជាតិ និងឯកជន។

**២-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** ណែនាំគ្រប់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត ចាត់តាំងឲ្យមានការសូត្រកំណាព្យ ការប្រគំតន្ត្រីបុរាណ សម័យ ចាប៉ី អាយ៉ៃឆ្លើយឆ្លង ដែលមានខ្លឹមសារពាក់ព័ន្ធទៅនឹងសន្តិភាព នៅតាមទីសាធារណៈ ដើម្បីប្រជាពលរដ្ឋបានចូលរួមកម្សាន្តសប្បាយផង និងទទួលបានខ្លឹមសារនៃទិវាសន្តិភាព ២១ កញ្ញា ផង។

**៣-<u>ក្រសួងធម្មការ និងសាសនា</u>** ណែនាំគ្រប់មន្ទីរធម្មការ និងសាសនារាជធានី ខេត្ត ចាត់តាំងឲ្យមានកម្មវិធីយល់ដឹងអំពីអត្ថន័យទិវាសន្តិភាព ២១ កញ្ញា តាមរយៈការសូត្រធម៌ សម្តែងធម៌ទេសនា តាមវត្តព្រះពុទ្ធសាសនា តាមវិហារឥស្លាមសាសនា គ្រិស្តសាសនា និងសាសនាផ្សេងៗ ដើម្បីផ្សព្វផ្សាយសេចក្តីមេត្តាធម៌ ចំពោះមនុស្សសត្វទូទៅ និងសុំសេចក្តីសុខសន្តិភាព សម្រាប់មនុស្សជាតិនៅលើពិភពលោក ព្រមទាំងណែនាំគ្រប់វត្តអារាម តុបតែងលម្អទង់ជាតិ បដាពាក្យស្លោក និងបំភ្លឺភ្លើងពណ៌អបអរសាទរ។

ផ្ទះលេខ ៤៦ ផ្លូវលេខ ២៤០ រាជធានីភ្នំពេញ Tel/Fax: (855) 023 986 370 - (855) 023 986 374 - (855) 023 213 956 E-mail: ck012755777@gmail

៤- ក្រសួងព័ត៌មាន ត្រូវរៀបចំកម្មវិធីឲ្យបណ្តាញឃោសនាទាំងអស់មាន វិទ្យុ ទូរទស្សន៍ សារព័ត៌មានរដ្ឋ និងឯកជន ធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយ អំពីអត្ថន័យខ្លឹមសារនៃទិវាសន្តិភាព ២១ កញ្ញា និងរៀបចំឲ្យមានការជួបសម្ភាសន៍ជាមួយព្រះសង្ឃ ឥស្សរជនសំខាន់ៗ បញ្ញវន្ត ប្រជាជន មហាជន កម្មករ និយោជិត សិស្ស និស្សិត ។ល។

៥-ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបំផុសលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ ពន្យល់សិស្ស និស្សិត ឲ្យយល់ដឹងពីស្មារតីទិវាសន្តិភាពអន្តរជាតិ ២១ កញ្ញា ជាទិវាគ្មានអំពើហិង្សា និងបញ្ឈប់ការផ្ទុះអាវុធ ។

៦-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានី និងគ្រប់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ រោងចក្រ សហគ្រាស អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ត្រូវបំផុសមន្ត្រីរាជការ បុគ្គលិក និយោជិត កម្មករ និយោជក យុវជន និងប្រជាពលរដ្ឋ ឲ្យយល់ដឹងទិវាសន្តិភាពអន្តរជាតិ ២១ កញ្ញា ជាទិវាគ្មានអំពើហិង្សានិងបញ្ឈប់ការផ្ទុះអាវុធទូទាំងសកលលោក និងណែនាំឲ្យតុបតែងលម្អទង់ជាតិ ទង់ក្អែប បដាពាក្យស្លោក បំភ្លឺភ្លើងពណ៌តាមក្រសួង អង្គភាព អគារសាធារណៈ ក្រុមហ៊ុន រោងចក្រ សហគ្រាស សាលារៀន តាមសួនច្បារ ទីធ្លាសាធារណៈ និងតាមផ្ទះប្រជាពលរដ្ឋ។

៧-រាជធានី និងគ្រប់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវចាត់តាំងរៀបចំឲ្យមានការជួបសំណេះសំណាលនៅក្នុងក្របខ័ណ្ឌរាជធានី និងខេត្តរបស់ខ្លួន ដោយមានមន្ត្រីរាជការ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ សិស្ស និស្សិត និងប្រជាពលរដ្ឋចូលរួម។ ចាត់តាំងឲ្យមានសម្តែងសិល្បបុរាណ សម័យ ផ្សារភ្ជាប់ទៅនឹងខ្លឹមសារសន្តិភាព និងមានតុបតែងលម្អទង់ជាតិ ទង់ក្អែប បដាពាក្យស្លោក បំភ្លឺភ្លើងពណ៌ តាមគ្រប់មន្ទីរជុំវិញរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

៨-ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រៀមលក្ខណៈដោះស្រាយសម្ភារ ថវិកា ជូនក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលត្រូវចំណាយជាក់ស្តែងចាំបាច់ សម្រាប់បម្រើទិវាដ៏មានសារសំខាន់នេះ ឲ្យបានសមស្របនិងទាន់ពេលវេលា។

៩-ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវណែនាំដល់អង្គភាពក្រោមឱវាទ ឲ្យសហការការពាររក្សាសន្តិសុខ សុវត្ថិភាព របៀបរៀបរយ សណ្តាប់ធ្នាប់សង្គម ចរាចរណ៍ បម្រើការរៀបចំទិវាសន្តិភាពអន្តរជាតិ ធានាបានសេចក្តីសុខក្សេមក្សាន្ត និងភាពសប្បាយរីករាយជូនប្រជាពលរដ្ឋយើង។

គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សង្ឃឹមថាទទួលបានផែនការណែនាំនេះ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានី ខេត្ត នឹងចាត់តាំងអនុវត្តទទួលបានលទ្ធផលល្អប្រសើរ សមស្របតាមគោលបំណង និងសំណូមពររបស់រាជរដ្ឋាភិបាល ។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៧

គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

ប្រធាន

សម្តេចចៅហ្វាវាំង វរធៀងជ័យ អធិបតីស្រីធ្ងារ គង់ សំអុល

កន្លែងទទួល

ក្រសួងព្រះបរមរាជវាំង

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋានរដ្ឋសភា

ទីស្តីការគណៈរដ្ឋមន្ត្រី

ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការ

"ដើម្បីជូនជ្រាប"

គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានី និងគ្រប់ខេត្ត

"ដើម្បីសហការអនុវត្ត"

ឯកសារ-កាលប្បវត្តិ

# ពាក្យស្លោក

## សម្រាប់ប្រើក្នុងទិវាសន្តិភាពអន្តរជាតិ ២១ កញ្ញា ២០១៧

១- ជយោ! ព្រះរាជាណាចក្រកម្ពុជា

២- ជាតិ សាសនា ព្រះមហាក្សត្រ

៣- ជយោ! សន្តិភាព និងការអភិវឌ្ឍ

៤- ជយោ! សន្តិភាព និងការបង្រួបបង្រួមជាតិ

៥- ពង្រឹងឧត្តមគតិសន្តិភាព និងបន្ទុះបន្ថយភាពតានតឹង

៦- ដោះស្រាយរាល់វិវាទ ដោយសន្តិវិធី

៧- បញ្ឈប់រាល់អំពើហិង្សា និងវិវាទនៅលើពិភពលោកទាំងមូល

៨- ថ្ងៃទី ២១ កញ្ញា ជាថ្ងៃគ្មានអំពើហិង្សា និងបញ្ឈប់ការផ្ទុះអាវុធនៅទូទាំងសកលលោក

៩- ទិវា ២១ កញ្ញា ជាទិវាអន្តរជាតិសម្រាប់ពលរដ្ឋគ្រប់រូប និងប្រជាជាតិទូទាំងពិភពលោក

១០- អបអរសាទរយ៉ាងក្លៀវក្លាខួបលើកទី១៥ ទិវាសន្តិភាពអន្តរជាតិ ២១ កញ្ញា